## យកលំនាំតាម

## ”គោលការណ៍គ្រឹះរបស់ព្រះគម្ពីរ និងទេវវិទ្យារបស់ដាយកូនា ”

## បទបង្ហាញក្នុងការប្រជុំពិគ្រោះយោបល់ពី ដាយកូនា និងការអភិវឌ្ឍន៍

## តាមបរិបទជនជាតិអាស៊ី

**ថ្ងៃទី ១៨-២២ ខែតុលា ឆ្នាំ២០០៥**

**នាទីក្រុងបាំងកក ប្រទេសថៃ**

**បណ្ឌិត Kjell Nordstokke**

**Adapted from “Biblical and Theological Foundation of Diakonia”**
**Presented to the**
**LWF Consultation on**
***Diakonia* and Development in Asian Context**
**October 18-22, 2005. Bangkok, Thailand**
**Dr. Kjell Nordstokke:**

# "គោលការណ៍គ្រឹះរបស់ព្រះគម្ពីរនិងទេវវិទ្យារបស់ដាយកូនា[1] "

*ឯកសារបង្រួញ និងយកលំនាំសំរាប់គោលបំណងនៃការបកប្រែ[2]*

## សេចក្តីផ្តើម

ពាក្យថា"ដាយកូនា" មិនសូវបានប្រើជាញឹកញាប់នៅក្នុងគ្រប់ក្រុមជំនុំ លូថេរ៉ានទាំងអស់ទេ។ អ្នកខ្លះគិតថា ដោយសារ"ដាយកូនា"មិនមែនជាពាក្យអង់គ្លេស ដែលមានពាក្យខ្លះទៀតងាយយល់ជាង មានដូចជាពាក្យ សង្គមកិច្ច រឺក៏ សកម្មភាពសង្គម។

ទោះជាយ៉ាងណាក៏ដោយ គម្រោងសង្ខេបនេះបង្ហាញពីមូលហេតុថា ហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីឱ្យយើងយល់ដឹងពីរបៀបរស់នៅក្នុងជីវិតក្រុមជំនុំយើង។ អត្ថបទនេះមានបំណងថា ដាយកូនាមានន័យស៊ីជំរៅ ហើយទូលំទូលាយជាងពាក្យផ្លូវលោកដូចជាពាក្យ "សង្គមកិច្ច " ឬ "សកម្មភាពសង្គម"ដែលសមស្របទៅនឹងមូលដ្ឋានគ្រឹះរបស់ព្រះគម្ពីរនិងទេវវិទ្យា ហើយបញ្ជាក់ពីការតភ្ជាប់គ្នារវាងសកម្មភាពសង្គម និង អត្តសញ្ញាណនៃគ្រីស្ទបរិស័ទយើង។

ពាក្យសង្គមកិច្ចនិងសកម្មភាពសង្គម ជាគំនិតផ្លូវលោក ដែលមានឥទ្ធិពលលើ "ការកសាង" សង្គមបែបគំរូសម័យថ្មី▲។ នេះមានន័យថា យើងពូកែគ្រប់គ្រាន់នឹង"ស្ថាបនា" ឬ "កសាង" សង្គមមួយល្អដែលបំរើមនុស្សលោក។ តែដាយកូនាន័យផ្សេងពីនោះ។ ដាយកូនាឆ្លុះបញ្ចាំងពីទស្សនៈទូទៅរបស់គ្រីស្ទបរិស័ទ ដែលនិយាយថា" ព្រះជាម្ចាស់យកព្រះហរទ័យទុកដាក់ នូវអ្វីដែលទ្រង់បានបង្កើត និងព្រះអង្គរំពឹងគិតថា យើងនឹងចូលរួមជាមួយទ្រង់ ក្នុងការប្រោសលោកិយឱ្យជា។

ទេវវិទ្យានៃ"ដាយកូនា"ផ្តល់ដំណឹងដល់ក្រុមជំនុំថា តើគួរធ្វើអ្វីនៅក្នុងលោកសព្វថ្ងៃនេះ រាប់បញ្ចូលទាំងផ្នែកព្រលឹងវិញ្ញាណនិង"ការចូលរួមក្នុងសង្គម" ដែលព្រះយេស៊ូវបាន បង្រៀននិងតម្រូវលើសពី "ការងារសប្បុរសធម៌▲"ទៅទៀត។ ទេវវិទ្យានៃដាយកូនា អាចនឹងជួយក្រុមជំនុំលូថេរ៉ានឃើញពី "ការងារល្អទាំងឡាយ" ៣ ជាផ្នែកដ៏មានសារៈសំខាន់នៃជីវិតគ្រីស្ទបរិស័ទ និងធ្វើឱ្យថយចុះនូវការភ័យខ្លាច ដែលភាគច្រើនតែងសង្កត់ធ្ងន់ថា "ការងារល្អ▲ " អាចធ្វើឱ្យទន់ខ្សោយដល់ស្មារតីយើងចំពោះសេចក្តីជំនឿ។

ការយល់ដឹងពីដាយកូនា ជួយយើងឱ្យរស់នៅក្នុងជីវិតនៃការបំរើដល់អ្នកដទៃ ពីព្រោះយើងចង់ចូលរួមក្នុងក្តីស្រឡាញ់នៃព្រះគ្រីស្ទ សម្រាប់ជួយអ្នកដែលកំពុងមានសេចក្តីត្រូវការចាំបាច់ គឺមិន

---

[1] បង្ហាញនៅការប្រជុំពិគ្រោះអំពី ដាយកូនា និងការអភិវឌ្ឍន៍ ក្នុងបរិបទជនជាតិអាស៊ី ១៨–២២ ខែតុលា ឆ្នាំ ២00៥ នាទីក្រុង បាំងកក ប្រទេសថៃ ដោយបណ្ឌិត **Kjell Nordstokke**

[2] យកលំនាំតាម ៩/0៧ ដើម្បីនឹងសម្របសម្រួលការបកប្រែជាភាសាខ្មែរសំរាប់បុគ្គលិកអង្គការ LWF និង CWS

[3] ការងារល្អប្រឆាំងនឹងសេចក្តីជំនឿ គឺជាការជជែកដ៏យូរលង់មកហើយក្នុងសង្គមគ្រីស្ទសាសនា

មែនសំរាប់តែការបំពេញកតព្វកិច្ចសីលធម៌ប៉ុណ្ណោះទេ។ "ដាយកូនា " គឺជាគំនិតគន្លឹះនៅក្នុងអត្តសញ្ញាណយើងជាគ្រីស្ទបរិស័ទ និងការងាររបស់យើងរួមគ្នាក្នុងបេសកកម្មរបស់ព្រះ។

## ដើមកំណើតដាយកូនា តាមព្រះគម្ពីរ (Biblical Root of Diakonia)

ពាក្យ **ដាយកូនា** (Diakonia) ជាភាសាក្រិក ហើយជាញឹកញាប់ត្រូវបានប្រើនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។

ចាប់ពីដើមកំណើត **ដាយកូន** (diakon) — មានពាក្យបី ត្រូវបានប្រើនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាភាសាក្រិក:

១. កិរិយាស័ព្ទ "ដាយកូនិន" (diakonein) គឺ **បំរើ**, ត្រូវបានប្រើ ៣៦ដង។
ឱ: លូកា ៤:៣៩, ៨:៣, ១៧:៨។

២. នាម " ដាយកូនា" (Diakonia) ការបំរើ/**បេសកកម្ម**, ត្រូវបានប្រើ ៣៣ដង។
ឱ: រ៉ូម ១១:១៣, ១២:៧, កូរិនថូសទី១ ១២:៥, កូរិនថូសទី២ ៥:១៨, ៨:៤។

៣. នាម "ដាយកូណូស" (diakonos) **អ្នកបំរើ**, ត្រូវបានប្រើ ២៩ដង។
ឱ: ភីលីព:១:១, ធីម៉ូថេទី១ ៣:៨-១៣, រ៉ូម ១៦:១។

ស័ព្ទនៃពាក្យអាចត្រូវបានបកប្រែតាមផ្លូវផ្សេងៗគ្នា, ប៉ុន្តែមានពាក្យបីដែលស្រដៀងគ្នាបំផុត:

១. បំរើតុ (អ្នកបំរើតាមហាង)

២. ជួយ ដល់អ្នកណាម្នាក់ក្នុងន័យធំទូលាយ (ជួយដោយឥតលក្ខខ័ណ្ឌ)

៣. ទទួលនូវបេសកកម្ម ឬកតព្វកិច្ចដ៏ជាក់លាក់ណាមួយ, មាននៅក្នុងអក្សរសាស្ត្រប៉ូលីន (Pauline) ជាញឹកញាប់គឺព័ន្ធកិច្ចនៃភាពជាអ្នកដឹកនាំនៅក្នុងក្រុមជំនុំ។

ពាក្យទាំងនេះមានតួនាទីយ៉ាងសំខាន់ក្នុងការឱ្យយល់ដឹងអំពី បេសកកម្មរបស់ព្រះយេស៊ូវក្នុងនាមជាបេសកជន▲ចុះមកលោះបាប▲ឱ្យមនុស្ស(ព្រះមែស៊ីរបស់ព្រះជាម្ចាស់)។ សាវ័ក▲របស់ព្រះអង្គទាំងអស់ ខ្វាយខ្វល់តែជាមួយនឹងអំណាចចេស្តានិងឋានៈ ប៉ុន្តែព្រះយេស៊ូវប្រាប់ពួកគេថា គេខុសហើយ។ សូម្បីតែ "**កូនមនុស្ស**–ព្រះយកនិស្ស័យសាច់ឈាមជាមនុស្ស" មិនបានមកដើម្បី**ឱ្យគេបំរើទេ** (deaconed) តែទ្រង់យាងមកដើម្បីបំរើ (deacon) ហើយប្រទានជីវិតទ្រង់ ដើម្បីប្រោសលោះមនុស្សជាច្រើន (លូកា ១០:៤៥)។ សូម្បីសាវករបស់ព្រះអង្គដែលជឿលើភាពជាអាទិទេពរបស់ទ្រង់ មិនបានយល់ដឹងពីអត្ថន័យជ្រាលជ្រៅនៃភាព**យកនិស្ស័យសាច់ឈាមជាមនុស្ស**▲របស់ព្រះអង្គថាទ្រង់ជាម្នាក់ ដែលមកបំរើនិងផ្តល់ជីវិតដើម្បីប្រោសលោះមនុស្សលោក។ ព្រះយេស៊ូវ សំដែងអំណាចផ្សេងៗធ្វើជាគំរូ ដែលមិនមែនជាអំណាចត្រួតត្រាលើគេទេ (exousia) តែគឺជាសិទ្ធអំណាចដើម្បីបំរើ និងសង្គ្រោះ ហើយទ្រង់មានអំណាចក្នុងការប្រគល់សិទ្ធិពេញលេញ▲ដល់អ្នកទន់ខ្សោយទៅវិញ ។

"បើមាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាចង់ធ្វើជាអ្នកធំ អ្នកនោះត្រូវជាអ្នកបំរើដល់អ្នក

ទាំងអស់ហើយ បើមាននរណាម្នាក់ក្នុងចំណោមអ្នករាល់គ្នាចង់ធ្វើជាលេខមួយ ត្រូវឱ្យអ្នកនោះជាបាវដល់គ្រប់គ្នា" (ម៉ាកុស ១០:៤២-៤៤)។

ជំនឿជាមូលដ្ឋានមួយចំនួន ទាក់ទងទៅនឹងការយកនិស្ស័យសាច់ឈាមជាមនុស្សរបស់ព្រះយេស៊ូវ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី:

- ទ្រង់មានពិតមែន ហើយមាន**វត្តមានឥឡូវ**នៅក្នុងជីវិតមនុស្សលោក, ទ្រង់ចូលរួមចំណែកក្នុងលក្ខណៈភាពជាមនុស្សធម្មតា,
- ដើម្បីឱ្យមានភាពស្និទ្ធស្នាលនឹងមនុស្ស ទ្រង់មាន**វត្តមានសកម្ម** ធ្វើចលនាជុំវិញ សង្កេត និងយល់ដឹងពីភាពពិតប្រាកដ ក្នុងជីវិតមនុស្ស,
- គឺជា**វត្តមាននៃអ្នកនាំពាក្យពីព្រះ**▲។ ព្រះយេស៊ូវ បានបរិហាភាពអយុត្តិធម៌ និងប្រព័ន្ធនៃការបែងចែកមនុស្ស
- តាមរយៈវត្តមានរបស់ទ្រង់ យើង**អាចឈាន**ទៅដល់**នគរព្រះ**▲ និងភាពខ្លាំងក្លារបស់វា,
- វត្តមានរបស់ទ្រង់នាំមកនូវ**ការប្រោសឱ្យជា ការបំផ្លាស់បំប្រែ សេចក្តីសង្គ្រោះ** ទ្រង់នាំមកនូវជ័យជំនះជីវិតលើសេចក្តីស្លាប់។

ការជឿអំពីព្រះយេស៊ូវយកនិស្ស័យសាច់ឈាមជាមនុស្សនេះ បានត្រូវស្រាយបំភ្លឺនៅក្នុងរឿងជាច្រើន ក្នុងព្រះគម្ពីរសញ្ញាថ្មី អំពីរបៀបដែលទ្រង់ធ្វើទំនាក់ទំនងជាមួយអ្នកក្រនិងអ្នកមានជម្ងឺ ព្រះអង្គការពារនិងប្រោសឱ្យជាដល់អ្នកដែលកំពុងមានសេចក្តីត្រូវការចាំបាច់។ នេះ គឺជា ដាយកូនារបស់ព្រះយេស៊ូវដែលបំពេញបេសកកម្មជាបេសកជនរបស់ទ្រង់:"ខ្ញុំជាម្នាក់ក្នុងចំណោម អ្នករាល់គ្នាដែលជាអ្នកបំរើ " (លូកា ២២:២៨)។

មានការយល់ឃើញផ្សេងៗគ្នាអំពីទស្សនៈដាយកូនារបស់ព្រះយេស៊ូវជាច្រើន ក្នុងនោះ មានចំណុចមួយ បានបញ្ជាក់ពី **ការបន្ទាបខ្លួនដោយមិនគិតពីខ្លួនឯង**-"ដើរក្នុងជំហាននៃការស្តាប់បង្គាប់រហូត ដល់ជីវិតបង់-ព្រះយេស៊ូវដើរតាមព្រះរហូតដល់ថ្ងៃស្លាប់ "(ភីលីព ២:៨)។ ឯទស្សនៈមួយទៀត បានផ្តោតលើការអនុវត្តន៍នៃ**សិទ្ធអំណាចនៃដាយកូនា**ដើម្បីសង្គ្រោះមនុស្ស ។ សិទ្ធអំណាចនេះ វាខុសគ្នាពីសិទ្ធិអំណាចដែលអ្នកគ្រប់គ្រងលើលោកិយនេះប្រើប្រាស់។ (ម៉ាកុស ១០) ពួកគេគ្រប់គ្រង**ពីលើ**។ សិទ្ធអំណាចរបស់គេប្រើដើម្បីត្រួតត្រា ធ្វើឱ្យមានសភាពស្ងាត់ និងគំរាមកំហែង។ សិទ្ធអំណាចរបស់ ដាយកូនា គឺ**សំរាប់**តែជាប្រយោជន៍ដល់មនុស្សគ្រប់រូប។ គឺជាសិទ្ធអំណាចដែលលើកស្ទួយដល់អ្នកដែលរងគ្រោះ ប្រោសឱ្យជា គ្មានការបែងចែក ប្រគល់សិទ្ធពេញលេញ ដល់អ្នកដែលគ្មានសិទ្ធអំណាច បំផ្លាស់បំប្រែមនុស្សឱ្យទៅជាអ្នកធ្វើការជា មួយគ្នាក្នុងចំការទំពាំងបាយជូរ▲ របស់ព្រះអង្គម្ចាស់។

**យើងត្រូវបានគេត្រាស់ហៅឱ្យចូលរួមក្នុងការងារដាយកូនា (Called to be a diaconal church)**

ពេលព្រះយេស៊ូវបានជួបសាវ័ករបស់ទ្រង់ក្រោយពេលដែលព្រះអង្គមានព្រះជន្មរស់ពីសុគតឡើងវិញ ទ្រង់មានបន្ទូលថា: "ដូចដែលព្រះវរបិតាចាត់ខ្ញុំឱ្យមក ខ្ញុំក៏ចាត់អ្នករាល់គ្នាដែរ " (យ៉ូហាន ២០:២១)។ ក្នុងអត្ថបទនេះ និងអត្ថបទផ្សេងៗទៀតមានការបន្តនិយាយពីបេសកកម្មរវាងព្រះយេស៊ូវ និងសាវ័ករបស់ទ្រង់ ហើយយើងយល់ថា ដាយកូនា មិនគ្រាន់តែសំដៅទៅរកបេសកកម្មរបស់ព្រះយេស៊ូវប៉ុណ្ណោះទេ តែក៏សំដៅទៅរកបេសកកម្មដែលបានប្រទានឱ្យសាវ័ករបស់ទ្រង់ផងដែរ។ គ្រីស្ទបរិស័ទជឿថា ការបន្តបេសកកម្មនេះ អាចប្រព្រឹត្តទៅបានពីព្រោះតែសាវ័កទាំងអស់របស់ទ្រង់ទទួលបាននូវព្រះវិញ្ញាណបរិសុទ្ធ(យ៉ូហាន ២០:២១) ហើយពួកគេមានកំលាំងចិត្តដែលទទួលបានពីទ្រង់ដើម្បីបំពេញបេសកកម្មដាយកូនាបន្ត។ ដូចដែលទ្រង់មានបន្ទូលថា "ដូចដែលព្រះវរបិតាចាត់ខ្ញុំឱ្យមក ខ្ញុំក៏ចាត់អ្នករាល់គ្នាដែរ"។ នៅពេលព្រះយេស៊ូវបានយកនិស្ស័យសាច់ឈាមជាមនុស្សនៅលើផែនដី ព្រះយេស៊ូវបានបំពេញបេសកកម្មដោះស្រាយបញ្ហាជាច្រើន អាស្រ័យដូចនេះហើយ ទើបពេលបច្ចុប្បន្ននេះ ពួកក្រុមជំនុំទាំងអស់ ត្រូវបំពេញបេសកកម្មដោះស្រាយបញ្ហាសព្វថ្ងៃដែរ។ ការដើរតាមគំរូព្រះយេស៊ូវ មានន័យថា យើងត្រូវតែមានវត្តមានយ៉ាងសកម្ម ជាពិសេសនៅទីកន្លែងណាដែលមានមនុស្សឈឺចាប់ និងត្រូវបានគេបោះបង់ចោល។

ដាយកូនានៃក្រុមជំនុំ ត្រូវប្រកាសផ្សព្វផ្សាយ ពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ និងលើកឡើងនូវការងារសំរាប់ប្រោសឱ្យជា ការផ្សះផ្សា និងការបំផ្លាស់បំប្រែ នៅកន្លែងណា ដែលមានមនុស្សត្រូវបានគេបោះបង់ចោល ។

*ដាយកូនា* គឺជា**ផ្នែកចាំបាច់**នៃអត្តសញ្ញាណរបស់ក្រុមជំនុំ។ *ដាយកូនា* គឺជាអ្វីដែលជាក្រុមជំនុំ និងជាអ្វីដែលក្រុមជំនុំប្រារព្ធពិធីជួបជុំគ្នាអធិស្ឋាន សរសើរដំកើងព្រះ▲ និងអធិប្បាយព្រះបន្ទូល (ការសូត្រធម៌) ព្រមទាំងការប្រកាសដំណឹងល្អ▲ នៅក្នុងការអធិប្បាយ នោះ។រូបខាងក្រោមនេះអាចមានប្រយោជន៍ ដើម្បីបង្ហាញពីសារៈសំខាន់នៃទំនាក់ទំនងទៅវិញទៅមករវាងការអធិប្បាយព្រះបន្ទូល ការប្រកាសដំណឹងល្អ និងដាយកូនា នៅក្នុងជីវិតនៃក្រុមជំនុំ▲ (koinonia[3] )



## ដាយកូនា និង ការអភិវឌ្ឍន៍ (Diakonia and Development)

តាំងពីឆ្នាំ ១៩៦០មក ក្រុមជំនុំជាច្រើនចូលរួមក្នុងការងារដែលហៅថាការងារអភិវឌ្ឍន៍។ ភ្នាក់ងារក្រុមជំនុំពាក់ព័ន្ធផ្សេងៗ ត្រូវបានបង្កើតឡើងនៅទាំងក្នុងប្រទេសជឿនលឿន▲ និងប្រទេសកំពុងអភិវឌ្ឍន៍▲ ដើម្បីបំពេញកាតព្វកិច្ចចម្បងក្នុងការប្រតិបត្តគំរោងនានានៃផ្នែកសុខភាព ការអប់រំ និងកសិកម្ម។ល។ រយៈពេលជាច្រើនឆ្នាំមកហើយ គំរោងទាំងនោះបានថវិកាមកពីរដ្ឋាភិបាលនានា ជាពិសេស មកពីប្រទេសជឿនលឿន ។

នេះជាមូលហេតុមួយ ដែលមនុស្សមួយចំនួនមិនស្រួលចិត្តជាមួយគំនិតនៃការអភិវឌ្ឍន៍ ពីព្រោះ វាឆ្លុះបញ្ចាំងពីទំនើបកម្មរបស់មនុស្សមួយចំនួននៃការកើនឡើងផ្នែកសេដ្ឋកិច្ចតាមគំរូអ្នកមានទាំងឡាយនៅក្នុងប្រទេសជឿនលឿន ដោយមិនគិតថ្លឹងថ្លែងពីឫសគល់ដែលនាំឱ្យមានការបែងចែករវាងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។ ដូចជាអត្ថន័យនៃអាណានិគមនិយមចាស់ និង អាណានិគមនិយមបែបថ្មីដែរ។ បញ្ហាជាងនេះទៅទៀតនោះ គឺការពឹងផ្អែកទៅលើទស្សនៈលោក ខាងលិច និង អំណាច ដើម្បីធានាឱ្យមានមូលនិធិ និងការប្រើប្រាស់មូនិធិនោះបាន។ ដូច្នេះ ការអភិវឌ្ឍន៍មិនពាក់ព័ន្ធនឹងសាសនាឡើយ។

### បេសកកម្មថ្មីរបស់ LWF ព្យាយាមចង្អុលបង្ហាញនូវជំរើសផ្សេងៗដែលជំរុញ "ការអភិវឌ្ឍន៍" ឱ្យមានការប្រគល់សិទ្ធិពេញលេញដល់អ្នកទន់ខ្សោយ និងផ្តល់សុខុមាលភាពខាងឯវិញ្ញាណផងដែរ។

"ទោះជាយ៉ាងណាក៏ដោយ ការយល់ដឹងពីអត្ថន័យ និងបំណងរបស់ការអភិវឌ្ឍន៍ បានផ្លាស់ប្តូរយ៉ាងខ្លាំងក្លា។ដូច្នេះដើម្បីធ្វើឱ្យសង្គមរួចផុតពីការលំបាកផ្សេងៗ និងផ្តល់សិទ្ធិស្របច្បាប់ឱ្យមនុស្ស ដែលគេមិនមានពីមុនមក ការអភិវឌ្ឍន៍ត្រូវបានផ្តោតទៅលើសុខុមាលភាពសង្គម វប្បធម៌ និងខាងឯវិញ្ញាណរបស់មនុស្ស ហើយវាលែងផ្តោតតែទៅលើសេដ្ឋកិច្ច និងសំភារៈទៀតហើយ។ ការយល់ដឹងបែបនេះ ការងារអភិវឌ្ឍន៍ជាផ្នែកទាំងមូលនៃបេសកកម្មរបស់ក្រុមជំនុំ ហើយជាដំណើរការនៃការបំផ្លាស់បំប្រែ និងការប្រគល់សិទ្ធិពេញលេញឱ្យអ្នកទន់ខ្សោយ។"[4]

ផ្ទុយទៅវិញ ចំពោះ"ការអភិវឌ្ឍន៍" គំនិតរបស់ដាយកូនា បានចាក់ឫសយ៉ាងជ្រៅតាំងពីដើមដំបូងនៃការកើតមានឡើងនៃក្រុមជំនុំមកម្ល៉េះ។ ដាយកូនា បង្ហាញពីទង្វើជាក់ស្តែងក្នុងពេលបច្ចុប្បន្ននេះ និង ស្ថិតស្ថេរដោយវិញ្ញាណ ហើយដឹងដោយអ្វី ដែលមើលឃើញ និងស្តាប់ឮ ។ ដាយកូនាអាចប្រព្រឹត្តទៅបានតាមសេចក្តីត្រូវការ និងសេចក្តីសង្ឃឹមរបស់គ្រីស្ទបរិស័ទ។

---

[4] បេសកកម្មក្នុងបរិបទ , ទំព័រ ៤៩-៥០ (Mission in Context, p. 49-50)

## ដាយកូនានៃការនាំពាក្យពីព្រះ (Prophetic Diakonia)

ចលនាដាយកូនាដែលចាប់ផ្តើមដំបូងនៅប្រទេសអាល្លឺម៉ង់ក្នុងអំឡុងឆ្នាំ ១៨៣០ ដោយសារការស្រលាញ់ និងគោរពអនុវត្តតាមច្បាប់ព្រះប្រចាំថ្ងៃយ៉ាងខ្ជាប់ខ្ជួនរបស់បុគ្គលម្នាក់ៗ▲ ។ ការនេះបានផ្តល់នូវបរិបទដើមសំរាប់ការស្វែងរកអត្ថន័យនៃពាក្យ "ដាយកូនា" ថាជា "ការបំរើដោយបន្ទាបខ្លួន" ត្រូវនឹងតួនាទីដែលចាស់ទុំក្នុងក្រុមជំនុំ▲បានបំពេញ ។ អ្នកបំរើការងារដាយកូនា ត្រូវបានគេរំពឹងទុកថាជា "អ្នកបំរើបន្ទាបខ្លួន"។ អ្នកបំរើបន្ទាបខ្លួននេះ បង្កើតនូវគំនិតថា "ដាយកូនា" គួរតែស្ងៀមស្ងាត់ សឹងតែមានលក្ខណៈដូចទាសករដែលមិនគួរបង្កហេតុឱ្យនរណាម្នាក់ ខឹង ឬ មិនចូលរួមក្នុងបញ្ហានយោបាយស្មុគស្មាញឡើយ។

ក្នុងទសវត្សរ៍ថ្មីៗនេះ ការបកប្រែនេះត្រូវបានគេសើរើឡើងវិញ។ អ្នកប្រាជ្ញខាងព្រះគម្ពីរដូចជាលោក **ហ្សនខូលីន (John Collins)**[5] បានស្រាវជ្រាវរកឃើញ និង សរសេរថា វាមិនមែនមានន័យថា "ការបំរើដោយបន្ទាបខ្លួនទេ" តាមពិតភាសាក្រិក មានន័យថា "កាតព្វកិច្ចមកពីមនុស្សសំខាន់ផ្តល់ឱ្យដល់នរណាម្នាក់ "។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី តែងតែនិយាយទាក់ទងទៅនឹងព្រះយេស៊ូវ និងបេសកកម្មដែលព្រះបានបញ្ជូនបេសកជនអោយមកសង្គ្រោះយើងរួចអំពីបាប"។ ដោយមានការយល់ដ៏ស៊ីជំរៅបែបនេះហើយ ទើបទស្សនៈនៃ**ការនាំពាក្យពីព្រះ(prophetic diskonia)**▲ បានបង្កើតឡើង។

ពាក្យ "ដាយកូនានៃការនាំពាក្យពីព្រះ"នេះ បានយកទៅប្រើយ៉ាងទូលំទូលាយក្នុងរង្វង់សាសនាគ្រីស្ទ ជាពិសេស ជាមួយគ្រីស្ទបរិស័ទនៅប្រទេសកំពុងអភិវឌ្ឍន៍ ហើយវាក៏ដូចគ្នាចំពោះក្រុមរបស់លូថេរ៉ានដែរ។ អង្គការ LWF បានរៀបចំការពិគ្រោះយោបល់គ្នាមួយនៅឆ្នាំ ២០០២ [6] ដែល និយាយទាក់ទងទៅនឹងប្រធានបទ "ដាយកូនានៃការនាំពាក្យពីព្រះ–prophetic diakonia "។[៧] នៅក្នុងលិខិតពិគ្រោះយោបល់នោះ បាននិយាយថា:

*"យើងទទួលស្គាល់ដោយការដឹងគុណចំពោះការងារដាយកូនាជាច្រើនបែប ដែលក្រុមជំនុំបានអនុវត្តរាប់សតវត្សរ៍កន្លងមក និងចាំបាច់ត្រូវបន្តនៅក្នុងពេលបច្ចុប្បន្នយើងនេះ។ ក៏ប៉ុន្តែឥឡូវយើងត្រូវផ្លាស់ប្តូរអោយមានលក្ខណៈជាទំរង់ដាយកូនានៃការនាំពាក្យពីព្រះច្រើនជាង។ ដោយសារមានការបណ្តាលចិត្តឡើងដោយព្រះយេស៊ូវ និងអ្នកនាំពាក្យពីព្រះមុនគ្រីសករាជផ្សេងៗដ៏ទៃទៀត ដែលជាអ្នកប្រឈមមុខជាមួយនឹងអ្នកមានអំណាច និង ប្រកាសឱ្យមានការផ្លាស់ប្តូរក្នុងសេចក្តី*

---

[5] Collins, John N.: ដាយកូនា. ការបកប្រែឡើងវិញ នៃសៀវភៅប្រភពបូរាណ. ទីក្រុង New York / Oxford 1990.

[6] Johannesburg, ប្រទេសអាហ្វ្រិកខាងត្បូង– ខែវិច្ឆិកា ឆ្នាំ២០០២.

[7] LWF: Prophetic Diakonia:"សំរាប់ការប្រោសពិភពលោកឱ្យជា"របាយការណ៍– Johannesburg, ប្រទេសអាហ្វ្រិកខាងត្បូង–ខែវិច្ឆិកា ឆ្នាំ២០០២.

*អយុត្តិធម៌ ហើយយើងអធិស្ឋានសូម ព្រះជាម្ចាស់ផ្ដល់កំលាំងឥទ្ធិពលជួយឱ្យយើងបំលាស់ប្ដូរអ្វីៗទាំងអស់ ដែលនាំឱ្យមនុស្សមានការលោភលន់ អំពើហឹង្សា អយុត្តិធម៌ និង ការបែងចែកវណ្ណៈ។*

ដូចនេះ *អ្វីទៅជាការនាំពាក្យពីព្រះ–prophetic diakonia?* ការនាំពាក្យពីព្រះ គឺជាពាក្យតាមព្រះគម្ពីរ និងត្រូវបានប្រើក្នុងបរិបទនោះ។

ដាយកូនានៃការនាំពាក្យពីព្រះទាក់ទងទៅនឹងអ្វីៗនៅក្នុងស្នូលនៃសារជាតិរបស់ដាយកូនា។ ចំនុចសំខាន់បំផុតរបស់ដាយកូនានៃការនាំពាក្យពីព្រះ គឺការបញ្ឈប់ភាពគួរសម ការធ្វើពុត ហើយ និងលើកទឹកចិត្តឱ្យគេហ៊ាននិយាយឡើង និងនិយាយតែការពិត ទោះបីជាការនិយាយនោះ ប៉ះពាល់ដល់របៀបរៀបរយ (ច្បាប់) ហើយ អ្នកនិយាយនោះត្រូវទទួលរងទុក្ខទោសក៏ដោយចុះ[8] ។

ក្នុងព្រះគម្ពីរអ្នកនាំពាក្យពីព្រះ(prophets)▲ គឺជាអ្នកការពារយុត្តិធម៌ដ៏រឹងមាំ ជាពិសេសនៅពេលដែលច្បាប់ព្រះប្រទានមកត្រូវបានគេមិនធ្វើតាម (មិនគោរពតាម)។ នេះ ត្រូវបានហៅថា ជាច្បាប់បង្កើតឡើងយ៉ាងច្បាស់មិនអាចប្រកែកបាន▲ (apodictic law)[9] ដែលបានធ្វើនៅលើភ្នំស៊ីណាយ ជាការព្រមព្រៀងរវាងព្រះជាម្ចាស់ និងរាស្ត្ររបស់ទ្រង់។ Apodictic law ដែលជាច្បាប់មិនអាចជំទាស់បាននេះ វាខុសគ្នាពីច្បាប់មានលក្ខណះសំរបសំរួល▲ (casuistic law) [10]ដែលបង្កើត ឡើងដោយមនុស្ស (អាចបកស្រាយពង្វាង ឬអាចចរចាបាន) វាគឺជាការព្រមព្រៀងរបស់យើងជា មួយព្រះជាម្ចាស់ និងសេចក្ដីសន្យា ថានឹងមានសេចក្ដីសុខសាន្ត និងសុខុមាលភាពក្នុងនគរព្រះ។

អ្នកនាំពាក្យពីព្រះ តែងតែយកព្រះបន្ទូលទៅផ្សព្វផ្សាយដល់អ្នកដឹកនាំសាសនា អ្នកមាន និងអ្នកមានអំណាច ដូចជាស្ដេច ជាដើម។ បច្ចុប្បន្ននេះ ដាយកូនានៃការនាំពាក្យពីព្រះ ត្រូវទទួលភារកិច្ចទៅប្រាប់ក្រុមជំនុំ ដើម្បីឱ្យសួរខ្លួនឯងថា តើយើងគ្រប់គ្នាដោះស្រាយបញ្ហាសព្វថ្ងៃនេះយ៉ាងដូចម្ដេច ។

តាមទំលាប់សាសនាគ្រីស្ទ អ្នកនាំពាក្យពីព្រះ (prophesy)▲ រាប់បញ្ចូលទាំងព្រះអង្គម្ចាស់ និងអំណាចរបស់ទ្រង់"ត្បិតមើល ព្រះដែលទ្រង់សូនធ្វើភ្នំទាំងប៉ុន្មាន ក៏បង្កើតខ្យល់ ហើយថ្លែងប្រាប់មនុស្សពីគំនិតដែលនៅក្នុងខ្លួនគេ ព្រមទាំងធ្វើឱ្យពេលព្រឹកព្រហាមទៅជាងងឹត ហើយបានយាងទៅ

---

[8] របាយការណ៍របស់ក្រុមជុំនុំក្នុងចលនាសង្គម

[9] ច្បាប់ថ្លែងក្នុងរបៀបឥតលក្ខខ័ណ្ឌដោយពុំមានខប្រាប់លក្ខណៈ, ច្បាប់ផ្ដាច់ការត្រូវបានញែកចេញដោយឡែកពីច្បាប់ក្ដី

[10]ច្បាប់ Casuistic បញ្ជាក់ច្បាស់ពីករណី– ចេញពីនាមគេ–និងត្រូវបានព្រៀងដោយលក្ខខ័ណ្ឌ របៀបថា ប្រសិនបើ–ដូចនេះ ឬពេលដែល– ដូចនោះ (សូមមើល និក្ខមនំ ២១: ១៨–១៩).

លើទីខ្ពស់ទាំងប៉ុន្មាននៃផែនដីផង ព្រះនាមរបស់ទ្រង់គឺ **យេហូវ៉ា**ជាព្រះនៃពួកពលបរិវារ" ដូចបាន អាននៅអេម៉ុស ៤:១៣។ **prophecy** ក៏សំដែងចេញផងដែរពីការព្រួយបារម្ភរបស់ព្រះ ចំពោះ ស្នាមព្រះហស្ថរបស់ទ្រង់ ជាពិសេស សំរាប់រាស្ត្ររបស់ទ្រង់។ **prophecy** ក៏បានរំលឹកមនុស្ស លោកផងដែរថា ទ្រង់គឺជាចៅក្រម និងព្រះដ៏ប្រោសលោះ តាំងពីឥឡូវនេះ និងជានិច្ចអស់កល្ប រៀងទៅ។

តើមានទំនាក់ទំនងអ្វីរវាង***ការនាំពាក្យពីព្រះនិងដាយកូនា?*** ទាំង*ការនាំពាក្យពីព្រះ និង ដាយកូនា* មានគោលដៅស្វែងរកឱ្យឃើញនូវដំណោះស្រាយទាំងឡាយ កសាងស្ពាន ស្វែងរកការ ចាប់ផ្តើមជាថ្មី ការប្រែចិត្ត និងការបំផ្លាស់បំប្រែ។ ជាអ្នកនាំពាក្យពីព្រះ មានន័យថា ជាអ្នកការពារ យុត្តិធម៌។ ហេតុដូច្នេះហើយ សកម្មភាពដាយកូនានៃការនាំពាក្យពីព្រះ រួមមានកាតព្វកិច្ចលាតត្រដាងអំពើអយុត្តិធម៌ និងផ្សព្វផ្សាយអំពើយុត្តិធម៌ ព្រមទាំងធ្វើជាអ្នកស្វែងរកផ្លូវល្អ ហើយនាំគេដើរ តាមផ្លូវនោះ។

## **បេសកកម្ម និង*ដាយកូនា*** **(Mission and *Diakonia*)**

ការពិគ្រោះយោបល់របស់អង្គការ LWF អំពី*ក្រុមជំនុំ* ក្នុងបេសកកម្ម [11] អះអាងបញ្ជាក់នូវអត្ថន័យនៃបេសកកម្មដូចតទៅ:

"*បេសកកម្មមានលក្ខណៈជាការប្រកាសដំណឹងល្អ ការបំរើ និងការតស៊ូមតិដើម្បីយុត្តិធម៌ ។* ***បេសកកម្មមានលក្ខណៈជាការប្រកាសដំណឹងល្អ*** *គឺជាបំណងប្រាថ្នារបស់គ្រីស្ទបរិស័ទគ្រប់រូបក្នុងការនិទានប្រាប់ និងបកស្រាយអំពីដំណើរជីវិតរបស់ព្រះយេស៊ូវនៅក្នុងបរិបទរបស់ខ្លួនដែលជាមធ្យោបាយស្វែងរកសេចក្តីសង្គ្រោះ និងការរស់នៅដ៏សុខសាន្តនៅលើផែនដី ។* ***បេសកកម្មមានលក្ខណៈជាការបំរើ*** *គឺបញ្ជាក់ពីផ្នែករបស់ដាយកូនានៃជំនឿរបស់គ្រីស្ទបរិស័ទ។ ដែលជំនឿនេះបានបង្រៀនពីសេចក្តីស្រលាញ់ និងធ្វើការសំរាប់ប្រគល់សិទ្ធិពេញលេញអោយអ្នកទន់ខ្សោយ និងរំដោះពួកគេឱ្យរួចផុតពីសេចក្តីទុក្ខលំបាកផ្សេងៗ។ ចំណែកឯ* ***បេសកកម្មមានលក្ខណៈជាការតស៊ូមតិដើម្បីយុត្តិធម៌****វិញ មានន័យថាជាសកម្មភាពសាធារណៈរបស់ក្រុមជំនុំ ដើម្បីបញ្ជាក់ម្តងហើយម្តងទៀត អំពីសេចក្តីថ្លៃថ្នូនៃជីវិតមនុស្ស ទាំងជាលក្ខណៈបុគ្គល និងជាលក្ខណៈសហគមន៍។ ហើយក៏វាមានន័យទូលំទូលាយផងដែរថា ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គម និង បរិស្ថាន"។*

ឯកសារថ្មីនៃបេសកកម្មរបស់អង្គការ LWF ឈ្មោះ *Mission in Context* បញ្ជាក់ពីអត្ថន័យ និងការយល់ដឹងដ៏ទូលំទូលាយនៃបេសកកម្ម[១២] និង គូសបញ្ជាក់ថា ជាបេសកកម្មគ្រប់ច្រុងជ្រោយៈ មានន័យថា ការប្រកាសដំណឹងល្អ▴ ការបំរើឬ ដាយកូនា និងការតស៊ូមតិ។ ដកស្រង់ចេញពីឯកសារពិគ្រោះយោបល់ខាងលើ ការនាំពាក្យពីព្រះ(prophetic diakonia) ក្នុងឆ្នាំ ២០០២ បានបញ្ជាក់ថា:

"***ដាយកូនា*** *គឺជាសមាសភាពស្នូលនៃដំណើរជីវិតរបស់ព្រះយេ៉ស៊ូវតែម្តង ដូច្នេះហើយទើបវាមានសារៈសំខាន់ ដូចទៅនឹងអ្វីដែលមានន័យថា "ជាក្រុមជំនុំ" នោះឯង។ ដាយកូនា មិនមែនគ្រាន់តែជាជំរើសប៉ុណ្ណោះទេ តែជាផ្នែកចាំបាច់មួយនៃការដើរតាមព្រះ។ តាមរយៈការជ្រមុជទឹក ពួកគេចូលជាសមាជិកក្រុមជំនុំ។គ្រីស្ទបរិស័ទត្រូវបានគេតំរូវអោយរស់នៅ និងដើរតាមផ្លូវ****ដាយកូនា****។ ការងារនេះ វាត្រូវចាប់ផ្តើមដំបូងដោយការបំរើដោយឥតលក្ខ័ណ្ឌដល់អ្នកជិតខាងដែលកំពុងត្រូវ*

---

[11] ប្រារព្ធឡើងនៅ Nairobi ក្នុងឆ្នាំ ១៩៩៨

[12] បេសកកម្មក្នុងបរិបទ: ការបំផ្លាស់បំប្រែ, ការផ្សះផ្សា, ការប្រគល់សិទ្ធិពេញលេញឱ្យអ្នកទន់ខ្សោយ។ វិភាគទានរបស់ LWF សំរាប់ការយលដឹង និងអនុវត្តផ្ទាល់នៃបេសកកម្ម។ ទីក្រុងហ្សឺណែវ ២០០៤. ទំព័រ ៧.

*ការចាំបាច់ ហើយទង្វើនេះ វាជាជំហានដំបូងដែល នឹងធ្វើអោយមានការផ្លាស់ប្តូរ និងបំផ្លាស់បំប្រែសង្គម*[13] ។

ឯកសារនៃបេសកកម្ម បង្ហាញគំនិតជាគន្លឹះបី សំរាប់ការបកប្រែនូវកាតព្វកិច្ចនេះ ក្នុងពិភពបច្ចុប្បន្ន: ការបំផ្លាស់បំប្រែ ការផ្សះផ្សា និងការប្រគល់សិទ្ធិពេញលេញឱ្យអ្នកទន់ខ្សោយ។ ពាក្យគន្លឹះទាំងអស់នេះ មានប្រយោជន៍សំរាប់ការយល់ដឹងអំពី ដាយកូនា។

**១. ការបំផ្លាស់បំប្រែ:** មានអត្ថន័យជ្រាលជ្រៅជាងការផ្លាស់ប្តូរសង្គម ឬការអភិវឌ្ឍន៍ទៅទៀត ។ អត្ថន័យទាំងពីរនេះ គឺបញ្ជាក់ថា យើងកសាងសង្គម។ នេះ វាធ្វើឱ្យយើងជឿជាក់នៅក្នុងទំនាក់ទំនងរវាងមូលហេតុ និង ឥទ្ធិពល ក្នុងសង្គមលោកយើងនេះ។

ទំហំនៃការបំផ្លាស់បំប្រែ គឺទូលំទូលាយណាស់។ ដូចជាការបញ្ជាក់របស់ទេវវិទូជនជាតិឥណ្ឌាម្នាក់ឈ្មោះ**ម៉ូនីកា ម៉េលេនថុន (Monica Melanchthon)** ថា *"ការបំផ្លាស់បំប្រែ ជាដំណើរការ នៃការប្តូរផ្លាស់ដែលត្រូវបានធ្វើឡើងនៅក្នុងរចនាសម្ព័ន្ធផ្សេងៗដូចជា: នយោបាយ សង្គម សេដ្ឋកិច្ច ឬវប្បធម៌ ជាដើម។ ដំណើរការនៃការបំផ្លាស់បំប្រែមានឥទ្ធិពលលើបុគ្គលម្នាក់ៗ ពីបុគ្គលម្នាក់ទៅម្នាក់ទៀត និងលើរចនាសម្ព័ន្ធសង្គមទាំងមូល។ រឿងដែលសំខាន់ដែរនោះ គឺ គ្រីស្ទបរិស័ទជឿថា អ្វីដែលថ្មីហើយប្លែក សុទ្ធតែកើតចេញមកពីឆន្ទ: និងស្នាមព្រះហស្តរបស់ព្រះ*[14] ។

ចេញពីទស្សនៈខាងលើ យើងដឹងថា ការបំផ្លាស់បំប្រែ ត្រូវមានវិញ្ញាណចូលរួមដែរ។ គ្មានមនុស្សណាម្នាក់អាចបំផ្លាស់បំប្រែខ្លួនឯងបានឡើយ។ ម្យ៉ាងវិញទៀត ព្រះមិនបានទាត់ចោលនរណាម្នាក់ចេញពីសេចក្តីសន្យានៃការបំផ្លាស់បំប្រែទេ។

យើងអាចប្រៀបធៀប "ការបំផ្លាស់បំប្រែ" ទៅនឹងឥទ្ធិពលនៃគ្រាប់ស្រូវដែលគេបានកប់ក្នុងដី ហើយមើលទៅដូចជាស្លាប់ ប៉ុន្តែបែរទៅជាលូតលាស់ចេញផ្លែផ្កាទៅវិញ ។ ការប្រៀបធៀបនេះ វាអាចរំលឹកយើងពីអាថ៌កំបាំងនៃការបំផ្លាស់បំប្រែ ដូចគ្នាទៅនឹងអ្វីដែលមើលទៅមិនសំខាន់ តែវាសំខាន់ទៅវិញ។ ចេញពីការប្រៀបធៀបខាងលើ អ្នកបំរើសហគមន៍យល់ថា "ដាយកូនា" មិនមែនជាសកម្មភាពខ្លាំងក្លាក្នុងការកសាងសង្គមទេ ប៉ុន្តែវាជាការបំរើ (service ) ចេញពីវិញ្ញាណព្រះ ។

---

[13] Idem, ទំព័រ. 37

[14] Melanchthon, Monica J.: Koinonia and Mission, in: ការប្រជុំពិគ្រោះយោបល់របស់ LWF អំពីក្រុំជុំនុំក្នុងបេសកកម្ម, ទីក្រុង Nairobi ខែតុលា ឆ្នាំ ១៩៩៨។ របាយការណ៍, ទំព័រ ១០៩-១១៧.

២. ប្រសិនបើការបំផ្លាស់បំប្រែចង្អុលបង្ហាញទាក់ទងខាងឯវិញ្ញាណនៃតួក្រុមជំនុំក្នុង ដាយកូនា នោះ **ការប្រគល់សិទ្ធិពេញលេញ▲** អោយអ្នកទន់ខ្សោយ **(empowerment)** ក៏យ៉ាងដូច្នោះដែរ។ ពាក្យថា empowerment នេះ ត្រូវបានប្រើជាលើកដំបូងក្នុងផ្នែកសកម្មភាពសង្គម និងនយោបាយ។ គោលបំណងចម្បងរបស់វា គឺរកឱ្យឃើញផ្លូវសំរាប់ប្រគល់សិទ្ធិពេញលេញដល់អ្នកទន់ខ្សោយ ប៉ុន្តែនៅពេលដែលយើងពិចារណាពីការប្រគល់សិទ្ធិពេញលេញ តាមការយល់ឃើញបែបទេវវិទ្យា វាទាក់ទងទៅនឹងព្រះបន្ទូលសន្យានៃថ្ងៃទី៥០ (Pentecost▲: ដូចដែលព្រះយេស៊ូវបានបង្ហាញវត្តមានរបស់ទ្រង់ ក្រោយពេលសុគតឱ្យសាវកបានឃើញ និងប្រគល់អំណាចដល់សាវក ដើម្បីបន្តបេសកកម្ម): "អ្នករាល់គ្នានឹងបានអំណាច នៅពេលព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតលើអ្នករាល់គ្នា ហើយអ្នកនឹងធ្វើបន្ទាល់ពីខ្ញុំ ... រហូតដល់ថ្ងៃអវសានផែនដីផង" (កិច្ចការ ១:៨)។

វាគឺជាជំនឿរបស់ក្រុមជំនុំដែលថាព្រះជាម្ចាស់បន្តប្រគល់សិទ្ធិពេញលេញដល់រាស្ត្ររបស់ទ្រង់ មិនមែនតែចំពោះអ្នកដឹកនាំប៉ុណ្ណោះទេ ប៉ុន្តែជាពិសេសអ្នកដែលគ្មានសំលេងក្នុងសង្គម។ ព្រះទ្រង់សំដែងព្រះគុណ និងអំណាចដោយការជ្រើសរើស "អ្វីដែលទន់ទាប និង អ្នកដែលគេស្អប់ខ្ពើម" (កូរិនថូស ទី១ ១:២៨)។ នៅក្នុងប្រទេសអាមេរិកឡាទីន ទស្សនៈស្របគ្នានៃការប្រគល់សិទ្ធិពេញលេញ គឺ "ភាពថ្លៃថ្នូរ ដែលផ្តល់ឱ្យមនុស្សទាំងអស់ ទាំងនៅក្នុងក្រុមជំនុំ និងក្នុងសង្គមទូទៅ–មានន័យថា ការការពារ និងលើកស្ទួយនូវកិត្តិយសរបស់មនុស្ស " ។

៣. សំរាប់គ្រីស្ទបរិស័ទវិញ **ការផ្សះផ្សា** គឺដំបូងសំដៅទៅលើសកម្មភាពរបស់ព្រះ ដែលធ្វើឱ្យមនុស្សមានទំនាក់ទំនងល្អឡើងវិញជាមួយព្រះជាម្ចាស់។ សំរាប់ហេតុផលដូចគ្នានេះ *ការធ្វើឱ្យមានភាពប្រសើរឡើងវិញជាមួយព្រះជាម្ចាស់* អាចបញ្ជាក់បានថា មានការបំផ្លាស់បំប្រែ និងការប្រគល់សិទ្ធិពេញលេញ ដើម្បីចូលរួមក្នុង *"ដាយកូនា*នៃការផ្សះផ្សា" (កូរិនថូសទី២ ៥:១៩)។ គមនិត*ដាយកូនា* រំលឹក យើងយ៉ាងច្បាស់ពី *ដាយកូនា*របស់ព្រះយេស៊ូវ ពីវត្តមានរបស់ទ្រង់ក្នុងចំណោមអ្នកក្រីក្រ គឺដើម្បីជួយលើកស្ទួយអ្នកដែលគេបោះបង់ចោល ការប្រោសឱ្យជា និងការប្រកាសនៃការអត់ទោស ព្រមទាំង ការកសាងជីវិតថ្មី។

## សំរាប់ការប្រោសពិភពលោកឱ្យជា (For the Healing of the World)

ក្នុងពិភពលោកដ៏ខ្ទេចខ្ទាំ *ដាយកូនា* ជាសេចក្តីត្រូវការចាំបាច់ដូចដែលការងារផ្សះផ្សា និងប្រោសឱ្យជា។ ***សំរាប់ការប្រោសពិភពលោកឱ្យជា*** គឺជាប្រធានបទចម្បងសំរាប់ មហាសន្និបាតលើក

ទី ១០ របស់អង្គការ LWF [15]។ ក្នុងពេលសន្និបាត ក្រុមអ្នកភូមិផ្សេងៗគ្នាបានពិភាក្សាលើប្រធានបទនេះ ដោយសារវាមានទំនាក់ទំនងទៅនឹងជីវិតរបស់ពួកគេ។ មានអ្នកភូមិមួយក្រុម បានផ្តោតលើការងារប្រោសឱ្យជារបស់ក្រុមជំនុំ។

**ខាងក្រោមនេះជាផ្នែកខ្លះនៃរបាយការណ៍ដែលគេបានចែកចាយ:**

*"ចំណុចចាប់ផ្តើមនៃការឆ្លុះបញ្ចាំងរបស់យើងទៅលើការងារប្រោសឱ្យជានៃក្រុមជំនុំ គឺថាព្រះជាម្ចាស់ជាអ្នកប្រោស។ យើងជឿព្រះជាម្ចាស់ថា ទ្រង់ជាជីវិត ហើយយើងឃើញការប្រោសឱ្យជា ដូចជាការលើកដំកើងឱ្យមានជីវិតពេញបរិបូរណ៍។ ដោយសារតែអំពើបាប លោកិយដែលយើងរស់នៅ កំពុងមានសភាពខ្ទេចខ្ទាំ ហើយមនុស្សជាអ្នករងគ្រោះដោយអំពើអយុត្តិធម៌ និងការជិះជាន់ពីអ្នកមានអំណាច។ ការប្រោសឱ្យជា ជាចំណែកនៃស្នាមព្រះហស្ដរបស់ព្រះជាម្ចាស់ ដែលក្នុងនោះមានការអត់ទោស និងការធ្វើឱ្យមានភាពប្រសើរឡើងវិញនៃទំនាក់ទំនងដែលខ្ទេចខ្ទាំ។*

*ដោយសារយើងជាក្រុមគ្រីស្ទបរិស័ទ យើងត្រូវបានព្រះត្រាស់ហៅជាដៃគូការងារប្រោសឱ្យជារបស់ទ្រង់។ ការប្រោសឱ្យជាដល់រូបកាយ និងវិញ្ញាណរបស់មនុស្ស សំខាន់ណាស់ក្នុងការងាររបស់ក្រុមជំនុំតាំងពីដើមមក និងបន្តរហូតដល់សព្វថ្ងៃនេះ។ ព្រះយេស៊ូវបានប្រោស និងត្រាស់ហៅអ្នកដើរតាមទ្រង់ឱ្យធ្វើការងារដូចជា "ចូរប្រកាសពីនគរព្រះ និងប្រោសឱ្យជា" (លូកា ៩:១-២)។ ការងារប្រោសឱ្យជា ជាការងាររបស់ក្រុមជំនុំទាំងមូលដែលបន្តការងារពីព្រះយេស៊ូវ ដើម្បីកសាង និង បង្រៀនសហគមន៍ថ្មី។ ការងារនេះ វារាប់បញ្ចូលទាំងការបំរើ (ដោយកូនា) -តាមរយៈការបំរើសេវាផ្នែកសុខភាព ការអប់រំ និងសង្គម សំរាប់អ្នកដែលមានសេចក្តីត្រូវការចាំបាច់។ អ្នករាល់គ្នាត្រូវបានត្រាស់ហៅដើម្បីចូលរួមលើកតំកើងការប្រោសឱ្យជា ការបណ្តុះបណ្តាល និងការថែរក្សាជីវិត។*

*នៅក្នុងពិភពលោកទាំងមូលយើងនេះ យើងមិនអាចកំរិតកាតព្វកិច្ចនៃការប្រោសឱ្យជាចំពោះ តែរង្វង់លក្ខណៈបុគ្គល ឬ អ្នកជិតជិតបានឡើយ ។ យើងត្រូវបង្កើនការយល់ឃើញឱ្យទូលំទូលាយ ដើម្បីប្រើប្រាស់ នៅក្នុងផ្នែកសង្គម នយោបាយ និងធម្មជាតិបរិស្ថានវិទ្យា។ នៅក្នុងការងារប្រោសឱ្យជារបស់ក្រុមជំនុំ មិនអាចបំភ្លេចការបំរើការងារព្រះបានទេ។ ទីណាមានការប្រោសឱ្យជា ទីនោះ ភាពយុត្តិធម៌កំពុងត្រូវបានធ្វើឱ្យមានភាពប្រសើរឡើងវិញ"។*

[15] Winnipeg 2003

នេះ គឺជាអត្តសញ្ញាណរបស់យើងដែលជាក្រុមជំនុំ**លូថេរ៉ាន**។ វាក៏ជាការងាររបស់យើងដែលយើងម្នាក់ៗបានទទួលតាមលក្ខខ័ណ្ឌដែលយើងរស់នៅ ហើយពេលជាមួយគ្នា វាក៏ជាការងាររួមគ្នាផងដែរ។ ដោយសារតែជាការងាររួម ដូចនេះ វាមិនមែនជាបន្ទុកដ៏ធ្ងន់ចំពោះយើងម្នាក់ៗទេ ប៉ុន្តែវាជាឱកាសសំរាប់ឱ្យយើងបានរួមដៃគ្នា ដើម្បីចែករំលែកការងារ និងធនធានទៅវិញ។

នៅក្នុងន័យនេះ យើងត្រូវរៀននិងជំរុញលើកទឹកចិត្តឱ្យគ្នាទៅវិញទៅមក ដើម្បីការងារដាយកូនា ជាមួយនឹងសេចក្តីសង្ឃឹម ដែលវិញ្ញាណព្រះផ្តល់អំណាចឱ្យយើងតាមព្រះបន្ទូលសន្យារបស់ទ្រង់: "ដូចនេះខ្ញុំជឿជាក់ថា ព្រះអង្គជាអ្នកធ្វើការល្អក្នុងអ្នករាល់គ្នា ហើយទ្រង់នឹងបន្តធ្វើការនេះ ទាល់តែដល់ថ្ងៃដែលព្រះយេស៊ូវយាងត្រលប់មកម្តងទៀត ដើម្បីជំនុំជំរះពិភពលោក" (ភីលីព ១:៦)។

**-ចប់-**

# សទ្ទានុក្រម

១. **ច្បាប់ព្រះ** – apodictic law: ច្បាប់បង្កើតឡើងយ៉ាងច្បាស់ មិនអាចប្រកែកបាន (understood it comes from God's Law)

២. **ពិភពលោកដ៏ខ្ទេចខ្ទាំ** – a broken world [តាមព្រះគម្ពីរ]: តាមព្រះគម្ពីរមានបញ្ជាក់ថាពិភពលោកយើងនេះ ជាពិភពដ៏ខ្ទេចខ្ទាំដោយអំពើបាប

៣. **ច្បាប់មនុស្សបង្កើត** – casuistic law[16]: ជាច្បាប់បង្កើតឡើងដោយមនុស្សមានលក្ខណៈសិរបសិរួល ផ្អែកលើករណីរឿងៈ ច្បាប់ដែលដោះស្រាយផ្អែកតាមករណីក្នុងវង្វង់លក្ខខ័ណ្ឌ–"if-then" or "when-then".....mode (see Exodus 21:18-19).

៤. **ការប្រារព្ធពិធីសាសនា** – celebration [leiturgia]: ការសំដែងនូវពិធីសាសនាផ្សេងៗ

៥. **ការងារសប្បុរសធម៌** – charity work [koinonia]: ការរៀបចំឬបង្កើតឡើងនូវការងារ ដើម្បី ជួយដល់អ្នកក្រីក្រដែលមានសេចក្តីត្រូវការចាំបាច់

៦. **ក្រុមជំនុំ** – church: គឺជាក្រុមគ្រីស្ទបរិស័ទដែលមានគោលិទ្ធិរបស់ខ្លួនច្បាស់លាស់ (អត្តសញ្ញាណ)

៧. **ប្រគល់អំណាចឱ្យ** – commissioned: ដែលទទួលបញ្ជា ឬអំណាចពីព្រះអង្គសំរាប់បំរើអ្នកដទៃ

៨. **ក្រុមមានជំនឿដូចគ្នា** – communion: សមាជិករបស់ក្រុមដែលមានជំនឿសាសនាដូចគ្នា

៩. **កិច្ចព្រមព្រៀង** – covenant: ការព្រមព្រៀងក្នុងទំនាក់ទំនងរវាងព្រះជាម្ចាស់ និងរាស្ត្ររបស់ទ្រង់

១០. **ថ្ងៃព្រះយេស៊ូវគ្រីស្ទយាងមកម្តងទៀត** -Day of Jesus Christ: គឺជាថ្ងៃដែលព្រះយេស៊ូវនឹងយាងមកលើផែនដីម្តងទៀតដើម្បីជំនុំជំរះមនុស្សលោក

១១. **ចាស់ទុំក្នុងក្រុមជំនុំ** – deaconesses and deacons: អ្នកដែលបានចាក់ប្រេងតាំងធ្វើជាអ្នកបំរើបន្ទាប់ពីបូជាចារ្យ គ្រូគង្វាល ឬអ្នក ដឹកនាំក្រុមជំនុំ (ចាស់ទុំប្រុសស្រីក្នុងក្រុមជំនុំ)

១២. **សាវ័កព្រះ** - disciples: អ្នកដែលបានដើរតាមព្រះយេស៊ូវផ្ទាល់រយៈពេលដែលទ្រង់មានព្រះជន្មរស់នៅលើផែនដី ជាពិសេស ជានរណាម្នាក់ក្នុងចំណោមសាវ័កទាំង១២របស់ទ្រង់

១៣. **បេសកជន** - God's Messiah: បេសកជនដែលព្រះបញ្ជូនអោយមកលោះបាប– ជាព្រះនាមរបស់ព្រះយេស៊ូវ

១៤. **ការងារល្អ** - good works:ការបំរើការងារ ដើម្បីជនទុរគត

[16] Casuistic laws specify a case— ច្បាប់ដែលនិយាយចំៗលើករណី — ចេញចំឈ្មោះ– និងដែលបានព្រៀងលើលក្ខខ័ណ្ឌដែលមានលក្ខណៈដូចជា ប្រសិនបើ– នោះនឹង ឬក៏ ពេលដែល– នោះនឹង (សូមមើល និក្ខមនំ ២១: ១៨–១៩)។

១៥. **ដំណើរជីវិតរបស់ព្រះយេស៊ូវ** – gospel: គឺដំណឹងល្អពីដំណើរជីវិតនៃព្រះយេស៊ូវគ្រីស្ទ ដែលបានសរសេរក្នុងសៀវភៅបួនក្បាលដំបូងក្នុងសញ្ញាថ្មី

១៦. **ព្រះវិញ្ញាណបរិសុទ្ធ** - Holy Spirit: ជាតួអង្គទីបីនៃព្រះត្រីឯក (ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ)

១៧. **ការយកនិស្ស័យសាច់ឈាមជាមនុស្ស** - incarnation: គឺព្រះបានយកនិស្ស័យសាច់ឈាម ជាមនុស្សរស់ដោយវិញ្ញាណនៃព្រះ (ព្រះយេស៊ូវ បុត្រានៃព្រះមានសាច់ឈាមជាមនុស្ស)

១៨. **យកនិស្ស័យសាច់ឈាមជាមនុស្ស** – incarnate: ដែលបានយកនិស្ស័យសាច់ឈាមជាមនុស្ស

១៩. **នគរព្រះ** - Kingdom of God (means the sovereign, the righteous rule of God. It is a rule in which power and goodness, judgement and mercy are combined. The presence of hope is critical to achieve the Kindom of God): ជាអធិបតេយ្យភាពត្រឹមត្រូវរបស់ព្រះ ដែលពោរពេញទៅដោយអំណាចល្អឥតខ្ចោះ និងមានការជំនុំ ជំរះដោយក្តី មេត្តាករុណារួមគ្នា ។ សេចក្តីសង្ឃឹមជាចំនុចសំខាន់បំផុតក្នុងការសំរេចឱ្យបាននគរព្រះ។

២០. **បេសកកម្ម** - mission: ប្រភេទនៃការបំរើ (ការផ្តល់សេវាផ្សេងៗ)

២១. **អ្នកងាកចេញពីប្រពៃណី** - modernist: ក្រុមមនុស្សក្នុងសិល្បៈ ឬសាសនា ដែលបែកចេញពីទំរង់ រឺគំនិតប្រពៃណី

២២. **បេសកកម្មរបស់បេសកជន** - Messianic mission - the specific work of Jesus as ”Messiah” on earth as foretold by the prophets in the Old Testiment, refer to the definition of <u>God’s Messiah</u>): ការងារពិសេសរបស់ព្រះយេស៊ូវ ដែលជាបេសកជន នៅលើផែនដីបានប្រាប់ជាមុននៅក្នុងសៀវភៅសញ្ញាចាស់ (មើលលេខ ១៣)

២៣. **ភ្នំស៊ីណាយ** - Mount Sinai: គឺភ្នំដែលលោកម៉ូសេបានទទួលនូវក្រិតវិន័យដប់ប្រការពីព្រះជាម្ចាស់សំរាប់រាស្រ្តទ្រង់

២៤. **ភាគខាងជើងនិងភាគខាងត្បូង** - the North and the South: ជាពាក្យដែលគេប្រើសំដៅទៅលើប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍

២៥. **ថ្ងៃទី ៥០** – Pentecost: គឺជាការប្រារព្វពិធីបុណ្យរបស់គ្រីស្ទានពីការដែលព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើសាវ័ករបស់ព្រះយេស៊ូវ ក្រោយពេលដែលព្រះអង្គត្រូវបានគេសំលាប់ និង ឡើងទៅស្ថានសួគ៍វិញ

២៦. **ដែលជឿ ស៊ប់** – pietistic:គុណភាពនៃការជឿយ៉ាងស៊ប់ ឬហួសហេតុ

២៧. **ការប្រតិបត្តិ** – praxis: ការអនុវត្តជាក់ស្តែងតាមច្បាប់

២៨. **ការប្រកាសដំណឹងល្អ** - proclamation/martyria (used in the Cirstian context means to announce the news that Jesus came to save us from sin): ត្រូវបានគេប្រើប្រាស់ការក្នុងបរិបទគ្រីស្ទាន មានន័យថា ប្រកាសពីដំណឹងល្អដែលព្រះយេស៊ូវចុះសង្គ្រោះមនុស្សលោកពីបាប។

២៩. **អ្នកនាំពាក្យពីព្រះ** – prophets: ជាពាក្យក្នុងព្រះគម្ពីរ (ច្រើនឆ្នាំកន្លងទៅ) អ្នកនាំពាក្យពីព្រះ ត្រូវបាន ព្រះជាម្ចាស់ផ្តល់អំណាច ដើម្បីឱ្យនិយាយប្រឆាំងទៅនឹងអ្នកមានអំណាច និងអ្នកដែលចាក ចេញពីព្រះ

៣០. **ការធ្វើឱ្យមានភាពប្រសើរឡើងវិញ** - restoration: ព្រះបានផ្សះផ្សាលោកិយឡើងវិញតាមរយៈព្រះ យេស៊ូវ

៣១. **ការរស់ឡើងវិញ** – resurrection: ព្រះគ្រីស្ទទ្រង់រស់ពីសុគតឡើងវិញ

៣២. **នៃទេវវិទ្យា** - theological: នៃការសិក្សាពីសារជាតិនៃព្រះនិងជំនឿសាសនា

៣៣. **ចំការទំពាំងបាយជូររបស់ព្រះ**– vineyard of the Lord (is metaphor frequently used in the Bible and often referring to God’s Church. ”I am the vine and you are the branches” John 15:5, អេសាយ ៥:៣-៧,ម៉ាកុស ១២:១-៩, ...): ការប្រៀបធៀបដែល បានប្រើ ប្រាស់ជាញឹកញាប់នៅក្នុងព្រះគម្ពីរ និងសំដៅទៅលើ ក្រុមជំនុំរបស់ព្រះ ។ ខ្ញុំ គឺជាដើមទំពាំងបាយជូរ ហើយអ្នកជាមែក ។

៣៤. **ប្រគល់សិទ្ធិពេញលេញ** – empowerment (to give full rights to the people): តាមការបក ប្រែពាក្យមានន័យថា"ការផ្តល់អំណាច" ប៉ុន្តែទោះយ៉ាងណាក៏ដោយ យើងបានជ្រើសយកការបកប្រែ ថា ជា"ការប្រគល់សិទ្ធិពេញលេញ" ពិព្រោះវាសមស្របនឹងបរិបទសង្គម ដូចជា: ពយកអាមេរិកឡាទីនបាន ជ្រើសយកទស្សនៈស្របគ្នានៃ"សេចក្តីថ្លៃថ្នូររបស់មនុស្ស(dignigication)

៣៥. **ដាយកូនានៃការនាំពាក្យពីព្រះ** – prophetic diakonia: ដាយកូនានៃការនាំពាក្យពីព្រះដែលព្រះបាន ចាត់បញ្ជូនមក

៣៦.**អំពើបាប**–sin (against God or a moral law):អំពើបាបដែលមនុស្សប្រព្រឹត្តប្រឆាំងនឹងច្បាប់ព្រះ